01130854

E329/10

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥

ភាសាដើម: អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Aug-2015, 14:30
CMS/CFO: Sann Rada

---

**ការធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ នួន ជា និង ខៀវ សំផន**

---

ដាក់ឯកសារជូនដោយ៖

វេជ្ជបណ្ឌិត Kin Ming CHAN

គ្រូពេទ្យជំនាញផ្នែកព្យាបាលមនុស្សចាស់

## សេចក្ដីផ្ដើម

1. ខ្ញុំ វេជ្ជបណ្ឌិត CHAN Kin Ming សន្យាជួយដល់អង្គជំនុំជម្រះសាលាដំបូងដោយសេចក្ដីស្មោះត្រង់ រក្សាការសម្ងាត់ និងបំពេញការងារឲ្យអស់ពីលទ្ធភាពរបស់ខ្ញុំ។

2. ខ្ញុំសូមដាក់ជូនរបាយការណ៍នេះ យោងតាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូង [1] និងលិខិតណែនាំ [2] ដែលលោក Matthew J. McCarthy មន្ត្រីច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង បានប្រគល់ជូនខ្ញុំនៅពេលខ្ញុំមកដល់ អ.វ.ត.ក។

3. ខ្ញុំត្រូវបានស្នើឲ្យសួរសំណួរខាងក្រោមនេះ ទាក់ទិននឹងការធ្វើតេស្ដលើសតិបញ្ញាស្មារតីរបស់ នួន ជា និង ខៀវ សំផន៖

   ក. តើត្រូវកែប្រែតេស្តនេះញឹកញាប់ប៉ុនណា? តើនរណាជាអ្នកទទួលខុសត្រូវក្នុងការកែប្រែតេស្តជាទៀងទាត់នេះ?

   ខ. តើនរណាពិតប្រាកដនៅអង្គភាពពេទ្យដែលនឹងធ្វើតេស្តនោះ? តើពួកគាត់រៀបចំផែនការបញ្ជូន និងដាក់លទ្ធផលនៃការធ្វើតេស្តនេះដោយរបៀបណា? ហើយតើនរណាជាអ្នកទទួលខុសត្រូវចំពោះរបាយការណ៍/ការដាក់ឯកសារទាំងនេះ? តើអាចមានការតែងតាំងវេជ្ជបណ្ឌិតទទួលបន្ទុកម្នាក់ដើម្បីទាក់ទងជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU) ដែរឬទេ?

   គ. ដោយសារតែការធ្វើតេស្តទៅលើជនជាប់ចោទ ត្រូវអនុវត្តរៀងរាល់បីខែម្តងនោះ តើអាចមានការកំណត់កាលវិភាគឲ្យហើយសម្រាប់ WESU ទទួលបានតេស្តដែលត្រូវបានធ្វើការដែរឬទេ?

## ការធ្វើតេស្តលើសតិបញ្ញាស្មារតីរបស់ នួន ជា និង ខៀវ សំផន

---

[1] ឯកសារ E138/1/10/1/5/9/7 ដីកាចាត់តាំងអ្នកជំនាញដើម្បីពិនិត្យ និងវាយតម្លៃសម្បទា អៀង ធីរិទ្ធ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥។

[2] លិខិតណែនាំសម្រាប់វេជ្ជបណ្ឌិត CHAN Kin Ming: ការត្រួតពិនិត្យទៅលើ អៀង ធីរិទ្ធ និងការធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ នួន ជា និង ខៀវ សំផន។

4. សេចក្ដីបញ្ជាក់របស់ខ្ញុំជូនតុលាការ គឺថា យើងមិនគួរអនុវត្តការពិនិត្យផ្លូវចិត្តត្រួសៗ (Mini Mental State Examination) ("MMSE") រៀងរាល់បីខែឡើយ ពីព្រោះលទ្ធផលអាចត្រូវបានប៉ះពាល់ដោយ "ឥទ្ធិពលនៃការដឹងរួចហើយ"។ ដូច្នេះ ខ្ញុំបានស្នើឱ្យប្រើប្រាស់ឧបករណ៍សាមញ្ញមួយ ហៅថា តេស្តត្រួសៗលើបញ្ញាស្មារតី (Abbreviated Mental Test) ("AMT")[3] ។ មិនដូចទៅនឹងការពិនិត្យ MMSE ដែលផ្ដល់ពិន្ទុក្នុងចំណោមពិន្ទុខ្ពស់បំផុត ៣០ នោះឡើយ តេស្ត AMT ផ្ដល់ពិន្ទុក្នុងចំណោមពិន្ទុខ្ពស់បំផុត ១០។ ក្នុងអំឡុងពេលដែលខ្ញុំជួបជាមួយនឹងសាស្ត្រាចារ្យ ចក ធីតា និងវេជ្ជបណ្ឌិត ឈួ ចាន់ណារ៉ា នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៥ នៅឯមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ពួកគាត់អាចធ្វើការកែប្រែបានទៅលើសំណួរចំនួនពីរក្នុងចំណោមសំណួរទាំងឡាយដែលត្រូវចោទសួរ៖

ក. សំណួរទី៣ នៅក្នុងបញ្ជីសំណួរ ៖ "សូមចាំអាសយដ្ឋាននេះ។ សូមប្រាប់អំពីអាសយដ្ឋាននេះឡើងវិញមកខ្ញុំ។ ខ្ញុំនឹងស្នើឱ្យលោកប្រាប់ពីអាសយដ្ឋាននេះឡើងវិញមកខ្ញុំ នៅចុងបញ្ចប់នៃការធ្វើតេស្តនេះ"។

អាសយដ្ឋានដែលបានផ្ដល់នោះគឺ ៣៥ មហាវិថី សម្ដេច សុធារស។

វេជ្ជបណ្ឌិតដែលធ្វើតេស្តអាចដាក់ជំនួសអាសយដ្ឋានមួយផ្សេងទៀតនៅក្នុងទម្រង់ដូចគ្នាដែលមាន លេខ និងឈ្មោះផ្លូវ។

ខ. សំណួរទី ៨ នៅក្នុងបញ្ជីសំណួរ៖ "តើកម្ពុជាទទួលបានឯករាជ្យពីបារាំងនៅឆ្នាំណា?"

សំណួរនេះ អាចជំនួសដោយសំណួរ "តើរបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា បានបញ្ចប់នៅឆ្នាំណា?"

5. ការផ្លាស់ប្ដូរសំណួរមួយចំនួនក្នុងចំណោមសំណួរទាំងឡាយដែលត្រូវចោទសួរ អាចជួយកាត់បន្ថយ "ឥទ្ធិពលនៃការដឹងរួចហើយ"។

6. ទាំងសាស្ត្រាចារ្យ ចក ធីតា និងវេជ្ជបណ្ឌិត ឈួ ចាន់ណារ៉ា នឹងជាវេជ្ជបណ្ឌិតដែលត្រូវបានចាត់តាំងឱ្យអនុវត្តការធ្វើតេស្ត AMT ហើយសាស្ត្រាចារ្យ ចក ធីតា បានយល់ព្រមធ្វើជាវេជ្ជបណ្ឌិតទទួលបន្ទុក។

---

[3] Hodkinson HM. Evaluation of a mental test score for assessment of mental impairment in the elderly. Age Ageing 1972, 1(4): 233-238.

7. អង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងសាស្ត្រាចារ្យ ចក ធីតា អាចកំណត់កាលវិភាគមួយដើម្បីអនុវត្តតេស្ត AMT។

8. តេស្ត AMT នឹងត្រូវធ្វើរៀងរាល់បីខែម្តង និងត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍វេជ្ជសាស្ត្រជាទៀតទាត់របស់ នួន ជា និង ខៀវ សំផន។ តេស្ត AMT មិនចាំបាច់ដាក់ជូនដាច់ដោយឡែកទៅតុលាការទេ ពីព្រោះវាគ្រាន់តែជាការវាយតម្លៃខ្លីដើម្បីកត់ត្រានូវដំណើរការសតិបញ្ញារបស់ពួកគាត់ក្នុងមួយឆ្នាំៗប៉ុណ្ណោះ។ ការវាយតម្លៃផ្នែកបញ្ញាស្មារតី "ដែលមានស្តង់ដាខ្ពស់ (gold standard)" គឺនៅតែជា ការពិនិត្យ MMSE ដដែល ដែលនឹងត្រូវធ្វើឡើងរាល់ឆ្នាំដោយអ្នកជំនាញដែលត្រូវបានតែងតាំងដោយតុលាការ។ ពិន្ទុរបស់ តេស្ត AMT ក្នុងរយៈពេលពេញមួយឆ្នាំ (ការវាយតម្លៃរៀងរាល់បីខែម្តង) នឹងជួយដល់អ្នកជំនាញដែលត្រូវបានតែងតាំងដោយតុលាការ ក្នុងអំឡុងពេលដែលគាត់វាយតម្លៃប្រចាំឆ្នាំទៅលើ នួន ជា និង ខៀវ សំផន។ ការធ្វើតេសនេះនឹងជួយបង្កើនទំនុកចិត្ត និងភាពត្រឹមត្រូវនៅក្នុងការកំណត់អំពីស្ថានភាពបញ្ញាស្មារតីរបស់ពួកគាត់។

9. តេស្ត AMT មួយឈុត គួរតែត្រូវបានដាក់ជាមួយនឹងរបាយការណ៍វេជ្ជសាស្ត្រ ពីព្រោះថា ពិន្ទុអាចត្រូវបានប៉ះពាល់ដោយជំងឺដែលអាចកើតមានចំពោះបុគ្គលនោះ។ ឧទាហរណ៍ ប្រសិនបើបុគ្គលនោះមានជំងឺគ្រុនក្តៅ ជំងឺនេះអាចប៉ះពាល់ដល់ពិន្ទុតេស្ត AMT ផងដែរ។ ដូច្នេះ ការប្រៀបធៀបទៅនឹងស្ថានភាពអ្នកជំងឺ *(Clinical Correlation)* គឺជាការចាំបាច់ណាស់ដើម្បីធ្វើការបកស្រាយលទ្ធផលពិន្ទុ។

10. តេស្ត AMT មួយឈុតផ្សេងទៀត អាចត្រូវដាក់ជាមួយគ្នា ដើម្បីងាយស្រួលក្នុងការតាមដានស្ថានភាពប្រែប្រួលនៃពិន្ទុ។

**ចុះហត្ថលេខា**

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥ | វេជ្ជបណ្ឌិត Kin Ming CHAN | រាជធានីភ្នំពេញ<br>ប្រទេសកម្ពុជា | [*ហត្ថលេខា*] |

**ឯកសារយោង៖**

តារាងពិន្ទុ AMT. Hodkinson HM. Evaluation of a mental test score for assessment of mental impairment in the elderly. Age Ageing 1972, 1(4): 233-238